# ការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សេចក្ដីផ្ដើម

សិទ្ធិនៅស្ងៀមមិនឆ្លើយតប (Right to Remain Silent) គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានសំខាន់ៗផ្សេងទៀតរបស់ជនជាប់ចោទ ដែលត្រូវបានធានាដើម្បីទទួលបានការជំនុំជម្រះក្ដីដោយត្រឹមត្រូវនិងយុត្តិធម៌ ។ សិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងមជ្ឈដ្ឋានច្បាប់ជាតិ និងអន្តរជាតិ ដូចជា កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយត្រូវបានអនុវត្តនៅតុលាការអន្តរជាតិមួយចំនួនដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(ICTY) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា(ICTR) និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន(SCSL) ។[១]

ដូច្នេះវាជាកត្តាសំខាន់ និងចាំបាច់ ដែលជនជាប់ចោទត្រូវយល់ដឹងអំពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរនៅពេលដំណើរការជំនុំជម្រះក្ដីក្នុងរឿងព្រហ្មទណ្ឌមកលើខ្លួន ។ នៅពេលជនសង្ស័យ ឬជនជាប់ចោទសម្រេចជ្រើសរើសយកសិទ្ធិនៅស្ងៀមមិនឆ្លើយតប នោះខ្លួននឹងមិនអាចត្រូវបានបង្ខំឲ្យឆ្លើយតបសំណួររបស់ភាគីណាមួយឡើយ ។ ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុសឡើយ ។[២] បញ្ញត្តិនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបកស្រាយថា ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយសំណួរដែលត្រូវបានសួរមកលើខ្លួនឡើយ ។ ដូច្នេះជនជាប់ចោទមានសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបសំណួររបស់ភាគី ។ លើសពីនេះទៀត វិធានផ្ទៃក្នុងរបស់តុលាការ

---

១-សូមមើលមាត្រា ៦៧(១)(ឆ) នៃលក្ខន្តិកៈរបស់ (ICC), មាត្រា ២១(៤)(ឆ) នៃលក្ខន្តិកៈរបស់(ICTY), មាត្រា ២០(៤)(ឆ) នៃលក្ខន្តិកៈរបស់ (ICTR) និងមាត្រា ១៧(៤)(ឆ) នៃលក្ខន្តិកៈរបស់ (SCSL) ។

២-សូមមើលច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ត្រង់មាត្រា ៣៥ថ្មី ចំណុច«ឆ» ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/legal/law-on-eccc

បានតម្រូវថា ជនសង្ស័យ និងជនជាប់ចោទត្រូវទទួលបាននូវការជូនដំណឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយតបនៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ក្នុងរឿងព្រហ្មទណ្ឌ ។[៣]

អត្ថបទនេះនឹងបង្ហាញអំពីជំហររបស់ជនជាប់ចោទនីមួយៗក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់មកនឹងបង្ហាញអំពីមូលដ្ឋានច្បាប់ និងទម្រង់ ឬវិសាលភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយចុងក្រោយនឹងលើកឡើងអំពីគុណសម្បត្តិ និងគុណវិបត្តិសម្រាប់ជនជាប់ចោទដែលអនុវត្តសិទ្ធិនេះ ។

# ១) ជំហររបស់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប

ទោះបីជនជាប់ចោទ អៀង សារី, ខៀវ សំផន និង នួន ជា ស្ថិតនៅក្នុងសំណុំរឿង០០២ តែមួយ ប៉ុន្តែជំហរក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទនីមួយៗ គឺមានលក្ខណៈខុសៗគ្នា ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីជំហររបស់ជនជាប់ចោទទាំងបីរូបដែលកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

## ១.១) ជំហររបស់ជនជាប់ចោទ អៀង សារី

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ (បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាស្នើសុំឲ្យមានការបញ្ជាក់អំពីចេតនារបស់ជនជាប់ចោទទាំងបីរូបពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម)[៤] ជនជាប់ចោទ អៀង សារី បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនផ្តល់សក្ខីកម្មឡើយ ពោលគឺរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរទាំងអស់របស់ភាគី ឬអង្គជំនុំជម្រះដែលមានបំណងសួរក្នុងអំឡុងពេលសវនាការទាំងមូល ។[៥] បន្ថែមលើនេះ អៀងសារី បានផ្ញើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ម្តងទៀតក្នុងអំឡុងពេលសវនាការថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ដោយបានបញ្ជាក់ថា “...ខ្ញុំបាទសូមប្រើប្រាស់សិទ្ធិ

---

៣-វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ វិធាន២១(១)(ឃ) ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/legal/15232

៤-សំណើរបស់សហព្រះរាជអាជ្ញា “ស្នើសុំសេចក្តីណែនាំទាក់ទងនឹងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម” ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។ ឯកសារលេខ E101 អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/14871

៥-សូមមើលឯកសារស្តីពី“ការជូនដំណឹងរបស់លោក អៀង សារី ទៅកាន់អង្គជំនុំជម្រះសាលាដំបូងថា លោកនឹងមិនផ្តល់សក្ខីកម្មទេក្នុងអំឡុងពេលសវនាការ” ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ។ ឯកសារលេខ E101/4 អាចរកបានក្នុងគេហទំព័រ : http://www.eccc.gov.kh/document/court/15806

របស់ខ្ញុំក្នុងរដ្ឋធម្មនុញ្ញ ដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរទាំងឡាយនាពេលនេះ ។ សិទ្ធិនេះមានចែងក្នុងមាត្រា៣១ និង៣៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំបាទមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុង ការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយ» ។[៦]

## ១.២) ជំហររបស់ជនជាប់ចោទ ខៀវ សំផន

ចំពោះជនជាប់ចោទ ខៀវ សំផន បន្ទាប់ពីប្រធានអង្គជំនុំជម្រះបង្គាប់ឲ្យបង្ហាញជំហររបស់ខ្លួនឲ្យបានច្បាស់ពាក់ព័ន្ធនឹងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប ខៀវ សំផន បានលើកឡើងថា ខ្លួនមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយពាក់ព័ន្ធនឹងអង្គហេតុស្ដីពីប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា ដរាបណាសហព្រះរាជអាជ្ញាមិនទាន់បង្ហាញភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុនេះ ។[៧] នៅសវនាការថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ជនជាប់ចោទ ខៀវ សំផន បញ្ជាក់បន្ថែម(តាមរយៈមេធាវីរបស់ខ្លួន) ថា ខ្លួននឹងមិនឆ្លើយសំណួរទាំងអស់ដែលទាក់ទងនឹងអង្គហេតុស្ដីពី «ប្រវត្តិសាវតាររបស់ជនជាប់ចោទ» ផងដែរ ។[៨] គួរបញ្ជាក់ថា ជនជាប់ចោទ ខៀវ សំផន មិនបានបង្ហាញជំហររក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅគ្រប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីទាំងមូលដូចជនជាប់ចោទ អៀង សារី ឡើយ ។ ពោលគឺគ្រាន់តែបញ្ជាក់ថាខ្លួនមិនឆ្លើយតបចំពោះសំណួរពាក់ព័ន្ធអង្គហេតុស្ដីពី «ប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា» និង «ប្រវត្តិសាវតាររបស់ជនជាប់ម្នាក់ៗ» ដែលត្រូវយកមកដេញដោលនៅក្នុងសវនាការដំណាក់កាលទីមួយតែប៉ុណ្ណោះ ។[៩]

## ១.៣) ជំហររបស់ជនជាប់ចោទ នួន ជា

សម្រាប់ជនជាប់ចោទ នួន ជា វិញ នៅអំឡុងពេលកិច្ចដំណើរការសវនាការដំណាក់កាលទីមួយ ខ្លួនមិនបានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរឡើយ ពោលគឺ នួន ជា បានឆ្លើយតបគ្រប់ភាគីទាំងអស់ដែលបានចោទសួរមកលើខ្លួន ។ ប៉ុន្តែមកដល់ពេលនេះ ជនជាប់ចោទ នួន ជា បានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ បន្ទាប់ពីអង្គជំនុំជម្រះប្រកាសបញ្ចប់សវនាការដំណាក់កាលទី១ ហើយបន្តដេញ

---

៦-សូមមើលប្រតិចារឹកសវនាការសម្រាប់ដំណាក់កាលដំបូងនៃសំណុំរឿង០០២ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារលេខE1/21/1 ទំព័រ៤០ បន្ទាត់ទី១០-១៤ ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/16362

៧-ឯកសារលេខ E1/21/1 ទំព័រ ៤៨ បន្ទាត់ទី ២-៨ ។

៨-សូមមើលប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង០០២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ឯកសារលេខ E1/26/1 ទំព័រ៥០ បន្ទាត់ទី ៤-៥ ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/16532

៩-ព័ត៌មានលម្អិតពាក់ព័ន្ធនឹងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ សូមមើលដីកាបំបែកកិច្ចដំណើរការនីតិវិធី ឯកសារលេខ E124 ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/15574

ដោលលើអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងតំណាក់កាលទី២ពាក់ព័ន្ធនឹង របនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីជនជាប់ចោទម្នាក់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទ នួន ជា បញ្ជាក់ជូនអង្គជំនុំជម្រះថា ប្រសិនបើអង្គជំនុំជម្រះមិនធ្វើការពិភាក្សាបន្ថែមលើអង្គហេតុពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា និងមិនដោះស្រាយនូវសំណើមួយចំនួនដែលខ្លួនបានស្នើសុំ នោះខ្លួននឹងរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរាល់សំណួរទាំងអស់ដែលនឹងត្រូវចោទសួរមកលើខ្លួន នៅក្នុងកិច្ចដំណើរការសវនាការដំណាក់កាលទី២នេះ ។[១០]

គួរបញ្ជាក់ថា រហូតមកដល់ពេលនេះ សំណុំរឿង០០២ដែលកំពុងដំណើរការនៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមិនមានជនជាប់ចោទណាម្នាក់ឆ្លើយតបនឹងសំណួរដែលភាគីមានបំណងចោទសួរឡើយ ពោលគឺជនជាប់ចោទទាំងអស់បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។

## ២) មូលដ្ឋានច្បាប់ និង ការបកស្រាយ ស្តីពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប

### ២.១) មូលដ្ឋានច្បាប់ដែលត្រូវយកមកអនុវត្ត

មូលដ្ឋានច្បាប់ក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ត្រូវបានលើកឡើងនៅពេលដែលជនជាប់ចោទ អៀង សារី ជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងថា ខ្លួននឹងមិនផ្តល់សក្ខីកម្ម ឬឆ្លើយតបសំណួរណាមួយដែលត្រូវបានចោទសួរដោយភាគីក្នុងអំឡុងពេលកិច្ចដំណើរការសវនាការឡើយ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកយកបទបញ្ញត្តិមួយចំនួនដែលអនុញ្ញាតឲ្យជនជាប់ចោទអាចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[១១] បទបញ្ញត្តិទាំងនោះរួមមាន៖

ទី១) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា៣១ ។ មាត្រានេះចែងថា“*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ*

---

១០-អាចរកមើលបន្ថែមនូវសេចក្តីថ្លែងការណ៍ទាំងស្រុងរបស់ជនជាប់ចោទ នួន ជា ក្នុងព្រឹត្តបត្រលេខ១១ ទំព័រទី២-៤ ចុះខែឧសភា ឆ្នាំ២០១២ នៃគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អាចរកបានក្នុងគេហទំព័រ: http://d.dccam.org/Projects/ECCC_Trial_Observation/pdf/Observation_11.pdf

១១-សូមមើលឯកសារស្តីពី “ការជូនដំណឹងរបស់លោក អៀង សារី ទៅអង្គជំនុំជម្រះសាលាដំបូងថា គាត់នឹងមិនផ្តល់សក្ខីកម្មទេ” ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ។ ឯកសារលេខ E101/4.1 អាចរកបានក្នុងគេហទំព័រ: http://www.eccc.gov.kh/document/court/15808

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ” ។

ទី២) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រង់មាត្រា១២(២) និងមាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រាទាំងពីរនេះបានចែងស្រដៀងគ្នា ដោយតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ឲ្យស្របតាមបទដ្ឋានអន្តរជាតិដូចដែលមានចែងក្នុងមាត្រា១៤ និង១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីធានាឲ្យបានការកាត់ក្តីប្រកបដោយត្រឹមត្រូវនិងយុត្តិធម៌ ។[១២]

ទី៣) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រង់មាត្រា១៤(៣)(ឆ) និងមាត្រា៣៥(ឆ)ថ្មីនៃច្បាប់បង្កើតអង្គជំនុំជម្រះ ដែលមាត្រាទាំងពីរនេះចែងដូចគ្នាថា ជនជាប់ចោទមានសិទ្ធិ“ មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស” ។

ទី៤) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រង់វិធាន ២១(១)(ឃ) ។ វិធាននេះចែងថា“ ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវបានផ្តល់ព័ត៌មានអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប” ។[១៣]

យោងតាមមូលដ្ឋានច្បាប់ដូចបានរៀបរាប់នេះ ជនជាប់ចោទ អៀង សារី អះអាងថាខ្លួនមានសិទ្ធិពេញលេញក្នុងការមិនផ្តល់សក្ខីកម្ម ឬរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតបនឹងសំណួរនៅគ្រប់កិច្ចដំណើរការនីតិវិធីរបស់តុលាការ ។

គួរបញ្ជាក់ថា មូលដ្ឋានច្បាប់ដែលបានលើកឡើងដោយមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺមិនត្រូវបានជំទាស់ដោយភាគីណាមួយឡើយ

---

១២- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/legal/agreement

១៣- វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិសោធនកម្មលើកទី៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។

ពោលគឺសិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងពេញលេញពីសំណាក់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ និងអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សហព្រះរាជអាជ្ញាបានបង្ហាញជំហរយ៉ាងច្បាស់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយអនុលោមតាមវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[១៤] ច្បាស់ជាងនេះទៅទៀត សហព្រះរាជអាជ្ញាបញ្ជាក់ថា ខ្លួននឹងមិនជំទាស់ចំពោះការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរឡើយ ។[១៥]

ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានជំទាស់ ឬបដិសេធអំពីមូលដ្ឋានច្បាប់ដែលទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទដែលត្រូវបានលើកឡើងដោយមេធាវីការពារក្តីឡើយ ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយយោងទៅមាត្រា៣៥(ឆ) ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ។[១៦]

## ២.២) ទម្រង់ និងអានុភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ

បន្ថែមលើការយល់ដឹងអំពីមូលដ្ឋានច្បាប់ផ្សេងៗដែលត្រូវយកមកអនុវត្ត ការដឹងអំពីទម្រង់ និងអានុភាពនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរក៏ជាកត្តាសំខាន់ ដើម្បីធានាថាសិទ្ធិនេះត្រូវបានអនុវត្តពេញលេញ ។

---

១៤-សូមមើលឯកសារលេខ E101 ត្រង់កថាខណ្ឌទី៣ ។

១៥-សូមមើលឯកសារស្តីពី«ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី សុំការបញ្ជាក់ថា សេចក្តីសន្និដ្ឋានតទល់មិនអាចត្រូវបានគេទាញយកពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទឡើយ នៅពេលគាត់ប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយរបស់គាត់» ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារលេខ E164/1 កថាខណ្ឌទី៦ និង១២ ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/court/16699

១៦-សូមមើលប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ ឯកសារ E1/63/1 ទំព័រ៣២ ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/19080 ។ មាត្រា៣៥(ឆ) ថ្មីនេះចែងថា ជនជាប់ចោទមិនអាចត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាខ្លួនមានកំហុសឡើយ ។

## ក) ទម្រង់នៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ

ការបកស្រាយអំពីទម្រង់ ឬវិសាលភាពនៃការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺកើតឡើងបន្ទាប់ពីលោកចៅក្រម ហ្សង់ម៉ាក ឡាវែរិញ ដាក់ឯកសារភស្តុតាងនៅចំពោះមុខភាគី ហើយលោកបានព្យាយាមសួរជនជាប់ចោទ ខៀវ សំផន ដើម្បីឲ្យបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្នុងការដាក់ឯកសារទាំងនោះ លោកចៅក្រមបានអានខ្លឹមសារខ្លីៗ ហើយស្នើឲ្យជនជាប់ចោទ ខៀវ សំផន **ធ្វើអត្ថាធិប្បាយ ធ្វើការកត់សម្គាល់ ផ្លាស់ប្ដូរយោបល់ បញ្ចេញប្រតិកម្ម ធ្វើការបញ្ជាក់** ឬ **ពន្យល់បន្ថែម**...ទៅលើខ្លឹមសារដែលលោកបានអាន ។ ប្រភេទនៃសំណើទាំងនេះត្រូវបានលោក គង់ សំអុន ជាមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន ធ្វើការជំទាស់យ៉ាងខ្លាំង ដោយលើកឡើងថា កូនក្ដីរបស់ខ្លួនកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ។ ការព្យាយាមចោទសំណួរម្ដងហើយម្ដងទៀត ឬស្នើឲ្យផ្ដល់យោបល់ ឬធ្វើអត្ថាធិប្បាយទៅលើភស្តុតាង ឬបញ្ហាណាមួយ គឺធ្វើឲ្យប៉ះពាល់ដល់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ លោកមេធាវីបានបន្ថែមថា«ការស្នើឲ្យលោក ខៀវ សំផន ផ្ដល់យោបល់ ឬក៏ធ្វើអត្ថាធិប្បាយនេះ គឺគ្រាន់តែជាការផ្លាស់ប្ដូររបៀបសួរប៉ុណ្ណោះ ការតាំងសំណួរហ្នឹងធ្វើគ្រាន់តែមិនឲ្យចេញជាសំណួរ គឺឲ្យទៅជាប្រយោគធម្មតា ដើម្បីឲ្យលោក ខៀវ សំផន ឆ្លើយតប ។ អ៊ីចឹងបានន័យថា សិទ្ធិក្នុងការមិនឆ្លើយហ្នឹងមិនត្រូវបានអនុវត្តទេនៅពេលនេះ គឺដូចគ្នាដដែល ។ បានន័យថា លោក ខៀវ សំផន ត្រូវតែឆ្លើយតប ។ អ៊ីចឹងការធ្វើដដែលៗបែបនេះវាបង្ហាញថាយើងកំពុងតែបង្ខំលោក ខៀវសំផន ឆ្លើយតប» ។[១៧]

ពាក់ព័ន្ធបញ្ហានេះដែរ ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី បានលើកឡើងថា «សំណើឲ្យធ្វើការបញ្ជាក់ ផ្ដល់យោបល់ ឬ ឆ្លើយតបទៅនឹងសំណួរ ឬឯកសារនានា គឺជាសំណើសុំឲ្យនិយាយពីព្រោះជនជាប់ចោទមិនអាចបញ្ជាក់ផ្ដល់យោបល់ ឬឆ្លើយតប ដោយមិននិយាយបានឡើយ ។ នៅពេលណាជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ សំណើសុំឲ្យធ្វើការបញ្ជាក់ ផ្ដល់យោបល់ ឬឆ្លើយតបទៅនឹងសំណួរ ឬឯកសារ គឺជាការបំពានដល់សិទ្ធិជាសារវ័ន្តរបស់

១៧-ឯកសារ E1/26/1 ទំព័រ៥៨ បន្ទាត់ទី២-១៣ ។

*ជនជាប់ចោទ ដែលជាសិទ្ធិទទួលបានការការពារពីរដ្ឋធម្មនុញ្ញក្នុងការនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង»* ។[១៨]

គួរបញ្ជាក់ថា ការបកស្រាយអំពីទម្រង់ ឬវិសាលភាពនៃការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន និង អៀង សារី គឺមិនត្រូវបានអង្គជំនុំជម្រះសាលាដំបូង ឬសហព្រះរាជអាជ្ញាធ្វើការជំទាស់ ឬបដិសេធឡើយ ។ ពោលគឺអង្គជំនុំជម្រះបានបង្ហាញជំហរយល់ស្របតាមការបកស្រាយរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ ជាក់ស្តែងអង្គជំនុំជម្រះបានសម្រេចទទួលយកសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ដោយសុំឲ្យចៅក្រម ឡាវីញ ហ្វូង់ម៉ាក បញ្ឈប់ការសួរដេញដោលជនជាប់ចោទតាមរយៈការប្រើវិធីសាស្ត្រដូចបានរៀបរាប់ខាងលើនេះ ។[១៩]

## ខ) អានុភាពនៃការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប

សំណួរសួរថា នៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ តើអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានចំពោះជនជាប់ចោទដែរឬទេ?

### ខ.១) អំណះអំណាងរបស់ក្រុមមេធាវីការពារក្តី

ក្រុមមេធាវីការពារក្តី អៀង សារី អះអាងថា *«នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប នោះគេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទឡើយ ។ សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតប មិនអាចមានន័យពេញលេញឡើយនៅពេលការប្រើសិទ្ធិនេះនាំឲ្យមានការស្តីបន្ទោស ។ ការទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមាននៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺជាការបំពានដល់សច្ចធារណ៍នៃនិរទោស(ភាពគ្មានទោស) និងផ្ទេរបន្ទុកស្វែងរកភស្តុតាងពីការិយាល័យសហព្រះរាជអាជ្ញាទៅជាបន្ទុករបស់មេធាវីការពារក្តី»* ។[២០]

---

១៨-សូមមើលឯកសារស្តីពី«សំណើរបស់ អៀង សារី ស្នើសុំការបញ្ជាក់ពីការមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ នៅពេលជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប» ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២(សំណើរបស់ អៀង សារី) ឯកសារលេខ E164 ត្រង់កថាខណ្ឌទី ៩ ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/court/16586

១៩- ឯកសារ E1/26/1 ទំព័រ៥៨ បន្ទាត់ទី១៨ ដល់ទំព័រ៥៩ បន្ទាត់ទី៤ ។

២០-សំណើរបស់ អៀង សារី ត្រង់កថាខណ្ឌទី១០ ។ គួររំឭកមាត្រា៣៨ កថាខណ្ឌ៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថា«ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ ចំណែកវិធាន

ក្រុមមេធាវីការពារក្តីបន្ថែមទៀតថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា វិធានផ្ទៃក្នុង កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានចែងពីលទ្ធភាពដែលអាចទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានចំពោះជនជាប់ចោទដែលប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរឡើយ ។ ផ្ទុយមកវិញ បញ្ហានេះបានកំណត់នៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានកំណត់ថា ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ហើយការនៅស្ងៀមស្ងាត់នេះមិនត្រូវយកមកពិចារណាក្នុងការកំណត់ថា ជនជាប់ចោទនោះមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពឡើយ ។ មានការសម្រេចស្រដៀងគ្នារបស់តុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក្នុងរឿងក្តី Celebici និង Delalic ដោយបានសម្រេចថា *“...លក្ខន្តិកៈ និងវិធាន មានចែងពីការហាមឃាត់ដាច់ខាត ប្រឆាំងនឹងការចាត់ទុកការនៅស្ងៀមមិនឆ្លើយតប ជាកត្តាមួយក្នុងការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោស”* ។[២១]

គួររំឭកថា សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ហើយដែលមិនអាចយកមកវិនិច្ឆ័យពីភាពមាន ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំង៩ ដែលជនជាប់ចោទត្រូវតែមាន (សិទ្ធិដែលត្រូវបានធានាក្នុងកម្រិតអប្បរិមា) ដើម្បីទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។[២២]

### ខ.២) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

ផ្ទុយពីការលើកឡើងរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី អង្គជំនុំជម្រះសាលាដំបូងអះអាងថា តាមយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា ការណ៍ដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀមមិនឆ្លើយតបសំណួរ នោះអាចត្រូវបានប្រើក្នុងការទាញចេញជាសេចក្តីសន្និដ្ឋានផ្ទុយ ។ គួរបញ្ជាក់ថា ការអះអាងនៅក្នុងសេចក្តីសម្រេចដោយផ្ទាល់មាត់នេះ អង្គជំនុំ

---

៨៧(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា“ ...សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ” ។

២១-សំណើរបស់ អៀង សារី ត្រង់កថាខណ្ឌទី១២

២២-លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ(ចូលជាធរមានថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២) ត្រង់មាត្រា៦៧ស្តីពីសិទ្ធិរបស់ជនជាប់ចោទ ។ អាចរកបានក្នុងគេហទំព័រ http://www.icc-cpi.int/Menus/ICC/Legal+Texts+and+Tools/

ជម្រះមិនបានលើកយករឿងក្តីជាក់លាក់ ឬយុត្តិសាស្រ្តរបស់តុលាការអន្តរជាតិណាមួយមកបង្ហាញឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះបញ្ជាក់ថា ក្នុងការវិនិច្ឆ័យអំពីកំហុសរបស់ជនជាប់ចោទខ្លួននឹងមិនផ្អែកទាំងស្រុងលើការទាញសេចក្តីសន្និដ្ឋានផ្ទុយចេញពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរឡើយ ។ ពោលគឺអង្គជំនុំជម្រះនឹងពិចារណាលើភស្តុតាងទាំងអស់ដែលបានដាក់ចំពោះមុខខ្លួនរួមទាំងសក្ខីកម្ម និងរបៀបដែលជនជាប់ចោទផ្តល់សក្ខីកម្ម ។ តាមអត្ថន័យនៃសេចក្តីសម្រេចនេះបញ្ជាក់ឲ្យឃើញថា នៅពេលដែលជនសង្ស័យ ឬជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ នោះអង្គជំនុំជម្រះនៅតែអាចមានលទ្ធភាពទាញសេចក្តីសន្និដ្ឋានជាអវិជ្ជមានក្នុងកម្រិតណាមួយ ដើម្បីវិនិច្ឆ័យអំពីកំហុសរបស់ជនសង្ស័យ ឬជនជាប់ចោទបាន ។ ជាក់ស្តែងអង្គជំនុំជម្រះបញ្ជាក់ថា“...*នៅពេលដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងការផ្តល់សក្ខីកម្ម នោះអង្គជំនុំជម្រះអាចនឹងកត់សម្គាល់អំពីបញ្ហានេះនៅពេលវាយតម្លៃអំពីភាពគួរឲ្យជឿជាក់បានរបស់គាត់*”[២៣] ។

## ៣) គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប

មានសំណួរជាច្រើនត្រូវបានចោទសួរឡើងជុំវិញការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួររបស់ជនជាប់ចោទក្នុងសំណុំរឿង០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណួរមួយចំនួនក្នុងចំណោមសំណួរទាំងនោះរួមមាន៖ តើមានផលប្រយោជន៍ និងផលវិបាកអ្វីខ្លះនៅពេលជនសង្ស័យ ឬជនជាប់ចោទសម្រេចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ? តើកិច្ចដំណើរការនីតិវិធីរបស់តុលាការនឹងប្រព្រឹត្តទៅដោយរបៀបណា? តើជនជាប់ចោទអាចការពារខ្លួនដោយរបៀបណា?

បញ្ហាទាំងនេះត្រូវបានស្រាយបំភ្លឺតាមរយៈការអនុវត្តជាក់ស្តែងនៅក្នុងកិច្ចដំណើរការជំនុំជម្រះក្តីលើសំណុំរឿង០០២នេះ ។ មានផលប្រយោជន៍ជាច្រើនសម្រាប់ជនជាប់ចោទ ដែលកើតចេញពីការសម្រេចចិត្តប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ ទី១) រហូតមកដល់ពេលនេះ គ្មានជនជាប់ចោទណាម្នាក់ ត្រូវបានភាគី ឬអង្គជំនុំជម្រះបង្ហាញឲ្យសារភាពកំហុស ឬឆ្លើយតបសំណួរណាមួយដែលដាក់បន្ទុកលើខ្លួនឯងឡើយ ។ គួរបញ្ជាក់ថា ជាច្រើនលើកច្រើនសារ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យជនជាប់ចោទផ្តល់សក្ខីកម្មអំពីអង្គហេតុដែលបានកើតនៅក្នុងរបបខ្មែរក្រហម ដើម្បីឲ្យ

---

[២៣] - សូមមើលឯកសារ E1/63/1 ទំព័រ៣២ បន្ទាត់ទី១៥ - ទំព័រ៣៣ បន្ទាត់៩ ។

ប្រជាជនកម្ពុជា និងសាធារណៈយល់ដឹងអំពីមូលហេតុនៃអំពើឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបនេះ ។ ប៉ុន្តែសំណើទាំងនេះមិនត្រូវបានពិចារណាឡើយ បន្ទាប់ពីមេធាវីការពារក្តីជនជាប់ចោទបង្ហាញជំហរថា កូនក្តីរបស់ខ្លួនកំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ ទី២) ពង្រឹងនូវតួនាទីរបស់សហព្រះរាជអាជ្ញាក្នុងការអនុវត្តកាតព្វកិច្ចបង្ហាញភស្តុតាង ដើម្បីបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។[២៤] ទី៣) ពង្រឹងតួនាទីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានភារកិច្ចចាត់វិធានការស៊ើបសួរ ដើម្បីឈានទៅរកការបង្ហាញការពិតនៃរឿងក្តី ។[២៥] ទី៤) ជនជាប់ចោទនៅតែអាចស្នើសុំធ្វើអត្ថាធិប្បាយទៅលើឯកសារភស្តុតាងណាមួយដែលត្រូវបានដាក់ចំពោះមុខខ្លួន ។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងនៅតែទុកលទ្ធភាពឲ្យជនជាប់ចោទធ្វើអត្ថាធិប្បាយលើភស្តុតាងណាមួយ ដែលយល់ថាមានប្រយោជន៍សម្រាប់ខ្លួន ទោះបីខ្លួនកំពុងតែប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបក៏ដោយ ។[២៦] គួរបញ្ជាក់បន្ថែមថា ទោះបីជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ប៉ុន្តែជនជាប់ចោទនៅតែមានសិទ្ធិណែនាំមេធាវីរបស់ខ្លួននៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ ។ មានន័យថា ក្នុងករណីមានភស្តុតាងណាមួយ ឬសក្ខីកម្មរបស់សាក្សីណាម្នាក់ដាក់បន្ទុកមកលើខ្លួន នោះជនជាប់ចោទមានសិទ្ធិណែនាំមេធាវីរបស់ខ្លួនដើម្បីធ្វើការជំទាស់ ឬបដិសេធចោល ។ ជាក់ស្តែងគឺការអនុវត្តរបស់ជនជាប់ចោទ អៀង សារី ។ ទោះបីជនជាប់ចោទរូបនេះរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរទាំងអស់ ប៉ុន្តែក្នុងកិច្ចដំណើរការសវនាការជនជាប់ចោទនៅតែធ្វើការណែនាំមេធាវីរបស់ខ្លួនជាប្រចាំ ដើម្បីតទល់ទៅនឹងសាក្សីណាដែលនឹងផ្តល់សក្ខីកម្មដាក់ទាក់ទងនឹងក្រសួងការបរទេស ដែលអាចដាក់បន្ទុកមកលើខ្លួន ។[២៧]

---

២៤-វិធាន៨៧នៃវិធានផ្ទៃក្នុងចែងថា«..សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជាប់ចោទ» ។

២៥-វិធាន៥៥(៥)នៃវិធានផ្ទៃក្នុងចែងថា«ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិតដោយអនុលោមតាមច្បាប់ ។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ» ។

២៦-សូមមើលសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ឯកសារលេខ E233 កថាខណ្ឌទី៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/22885 ។ គួរបញ្ជាក់ថា ទាំងមុន និងក្នុងអំឡុងពេលនៃការចេញសេចក្តីណែនាំនេះជនជាប់ចោទទាំងអស់ កំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅឡើយ ។

២៧-អាចរកមើលបន្ថែមក្នុងឯកសារស្តីពី«ពាក្យសុំលះបង់សិទ្ធិមានវត្តមានដោយមានដែនកំណត់ក្នុងកិច្ចដំណើរការសវនាការរបស់ជនជាប់ចោទ អៀង សារី» ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ ឯកសារលេខ E២២៩ ។ អាចរកបានក្នុងគេហទំព័រ៖ http://www.eccc.gov.kh/document/court/22629

ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២

ប៉ុន្តែទន្ទឹមគ្នានេះដែរ ក៏អាចមានផលអវិជ្ជមានមួយចំនួនសម្រាប់ជនសង្ស័យ ឬជនជាប់ចោទ ដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរនេះ ។ ពោលគឺពាក់ព័ន្ធនឹងតម្លៃ ឬទម្ងន់នៃភស្តុតាង ដែលជនសង្ស័យ ឬជនជាប់ចោទនោះបានផ្តល់ ។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាធ្លាប់បានដាក់សំណើសុំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យជូនដំណឹងទៅជនជាប់ចោទ ខៀវ សំផន ថា ក្នុងករណីជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ នោះចម្លើយទាំងឡាយណាដែលជនជាប់ចោទរូបនេះបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ នឹងមិនទំនងផ្តល់តម្លៃជាភស្តុតាងសំខាន់ៗឡើយ ។[២៨] ប៉ុន្តែរហូតមកដល់ពេលនេះ បញ្ហាតម្លៃ ឬ ទម្ងន់នៃភស្តុតាងដែលផ្តល់ដោយជនជាប់ចោទដែលប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ព្រោះអង្គជំនុំជម្រះមិនបានចេញសេចក្តីសម្រេចជាក់លាក់ណាមួយអំពីបញ្ហានេះឡើយ ។ ជាងនេះទៅទៀត វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏មិនបានចែងអំពីបញ្ហានេះដែរ ។

**ដោយ ចាន ប្រាថ្នា**

**ពិនិត្យដោយ វ៉ាន់ថាន់ ពៅដារ៉ា និង ឆាំង យុ**

២៨-សូមមើលលម្អិតឯកសារស្តីពី«សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយតបទៅនឹងសំណួរនៅក្នុងសវនាការ» ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារលេខ ៉១៧៤ កថាខណ្ឌទី២៦(ក) ។ អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/16869